TUKTUK

# បិសាចចម្លែកតូចៗ

## Teeny Tiny Monsters



Written by TukTuk

Illustrated by Choven Hen



មករាបានរត់ចូលទៅក្នុងបន្ទប់របស់រតនាបណ្ដើរ យំបណ្ដើរ។
រតនាក៏សួរទាំងភ្ញាក់ផ្អើល « តើមានរឿងអ្វីកើតឡើងហ្នឹង មករា? »





« បាទបង! ខ្ញុំយល់សប្តិឃើញរឿងអាក្រក់ណាស់  មានបិសាចចម្លែកតូចៗ រាប់ពាន់រាប់លានក្បាល ពួកវាចង់ធ្វើបាបខ្ញុំ ហើយវាបានព្យាយាមចូលក្នុង មាត់និងច្រមុះរបស់ខ្ញុំ »។





« ខ្ញុំបានខ្ទប់ដង្ហើមនិងយកដៃបិទច្រមុះរបស់ខ្ញុំ ហើយព្យាយាមរត់ចេញ ប៉ុន្តែពួកវា
នៅគ្រប់ទីកន្លែងទាំងអស់។ បន្ទាប់មក ខ្ញុំមិនអាចខ្ទប់ដង្ហើមបានទៀតទេ
ខ្ញុំក៏បើកមាត់ ហើយ... ហើយ... និង... »





រតនាបានឱប ហើយនិយាយលួងលោមទៅកាន់ប្អូន
« មករា! នៅទីនេះមិនមានបិសាចនោះទេ »។





មករាបានច្រានរតនាចេញ ហើយនិយាយ « បាទបង មានមែនតើ!
ថ្ងៃមុន លោកគ្រូសុខបានប្រាប់ពួកខ្ញុំអំពីវា។ វាគឺជាអ្វីតូចៗដែលមាននៅគ្រប់ទីកន្លែង។
វាពិតជាអាក្រក់ខ្លាំងណាស់។ ប្រសិនបើយើងមិនបានប្រុងប្រយ័ត្ន ពួកវាអាចចូលទៅក្នុងខ្លួន
យើង ហើយអាចធ្វើឱ្យពួកយើងឈឺបាន » « គេហៅពួកវាថា មេរោគ »។





រតនានិយាយទាំងញញឹម « អ៊ុំ... មែនហើយ! វាជាបិសាច។ គេហៅពួកវាថា មេរោគ។ ពួកវាមានរូបរាងតូចៗ មិនអាចមើលវាឃើញដោយភ្នែកទទេបានឡើយ ហើយវាអាក្រក់ខ្លាំងណាស់។ ពួកវារស់នៅគ្រប់ទីកន្លែង »។

រតនានិយាយទាំងចាក់ក្រឡេកប្អូន « នៅទីនេះៗ! នៅទីនោះៗ! នៅទីនេះៗ! »

នាងចាក់ក្រឡេកមកការហួតធ្វើឱ្យគាត់ស្រែកនិងសើចខ្លាំងៗ។





មករាបាននិយាយទាំងសម្លេងធំៗ « ឈប់លេងមើល! ខ្ញុំខ្លាចណាស់! ខ្ញុំមិនចង់ឱ្យមេរោគចូលក្នុងខ្លួនរបស់ខ្ញុំទេ ហើយខ្ញុំក៏មិនចង់ឈឺដែរ »។
រតនាខ្សឹបប្រាប់មករា « អ៊ីចឹង ចាំបងប្រាប់រឿងអាថ៌កំបាំងមួយដល់ប្អូនណា »។





« បងមានវិធីងាយៗ ដើម្បីកម្ចាត់មេរោគទាំងនោះ គឺត្រូវមានអនាម័យជានិច្ច។ វាមានន័យថា ពួកយើងត្រូវលាងសម្អាតដៃជាមួយសាប៊ូមុនពេលញ៉ាំអាហារ និងក្រោយពេលចូលបង្គន់រួច ព្រមទាំងងូតទឹកសម្អាតខ្លួនប្រាណ ហើយដុសធ្មេញរបស់ប្អូនផង »។










មករាបានចាប់ផ្តើមយំម្តងទៀត ហើយនិយាយ
« តើពួកវាមករកខ្ញុំដោយសារតែមូលហេតុបែបនេះមែនទេបង?
ព្រោះខ្ញុំភ្លេចលាងដៃជាមួយសាប៊ូបន្ទាប់ពីខ្ញុំទៅបង្គន់កាលពីយប់មិញ »





រតនានិយាយ « ចាំបងប្រាប់ប្អូននូវរឿងអាថ៌កំបាំងមួយទៀត។
នៅខាងក្នុងខ្លួនមនុស្សយើងមានអ្វីមួយដែលគេគ្រប់គ្នាហៅថាប្រព័ន្ធការពារសារពាង្គកាយ។
នៅពេលដែលវាឃើញមេរោគណាមួយនៅក្នុងខ្លួនរបស់យើង វានឹងបញ្ចេញកោសិកាឈាមស
ដើម្បីវាយប្រហារនិងសម្លាប់មេរោគនោះភ្លាម។
ពួកគេដូចជាទាហានដែលប្រយុទ្ធប្រឆាំងនឹងមនុស្សអាក្រក់ ហើយការពារយើងអ៊ីចឹងដែរ។
ពួកគេជួយការពារយើងមិនឱ្យឈឺបាន »។





មករាសួរទៀត « តើនេះជាមូលហេតុដែលយើងត្រូវលាងសម្អាតដៃមែនទេបង? »
រតនាឆ្លើយ « ចាស ពិតមែនហើយ! ប្រសិនបើមានមេរោគច្រើនពេកចូលក្នុងខ្លួនយើង
កោសិកាឈាមសក្នុងខ្លួនរបស់យើងវាមិនគ្រប់គ្រាន់ ដើម្បីសម្លាប់មេរោគទាំងអស់នោះទេ។
ដូច្នេះយើងលាងសម្អាតដៃ ដើម្បីជួយដល់ប្រព័ន្ធការពារសារពាង្គកាយរបស់យើងដែរ »។





មករាបន្តទៀត « ខ្ញុំគិតថាប្រព័ន្ធការពារសាពង្គកាយរបស់ខ្ញុំវាមិនដំណើរការទេ ព្រោះខ្ញុំមានអារម្មណ៍ថា មិនមានការប្រយុទ្ធគ្នាណាមួយនៅក្នុងខ្លួនខ្ញុំឡើយ »។ រតនាសើច ហើយនិយាយ « ប្អូនមិនអាចមានអារម្មណ៍ដឹងបាននោះទេ។ ប៉ុន្តែប្អូនអាចដឹងបាន នៅពេលដែលប្អូនមិនមានជំងឺឈឺនៅក្នុងខ្លួន »។





រតនានិយាយទៀត « ឱ្យលឿនមក បងឃ្លានហើយ! តោះញ៉ាំអាហារពេលព្រឹក
ជាមួយគ្នា! ប៉ុន្តែពួកយើងត្រូវធ្វើអ្វីសិន មុននឹងញ៉ាំអាហារ? »
មករាឆ្លើយ « បាទបង! គឺយើងត្រូវលាងសម្អាតដៃរបស់យើងជាមួយសាប៊ូជាមុនសិន »
« ចាស! មែនហើយ! បងចេះច្រៀងបទចម្រៀងមួយបទដែលនិយាយអំពីរបៀបលាងដៃ
ឱ្យបានត្រឹមត្រូវ ហើយយើងអាចច្រៀងវាពេលដែលយើងកំពុងលាងសម្អាតដៃបានណា »៕

♪ ស្កេន QR Code ដើម្បីទទួលបានបទចម្រៀង






# បិសាចចម្លែកតូចៗ

អ្នកនិពន្ធ៖TukTuk

អ្នកគំនូរ៖ ហ៊ិន ឆវិន

គំនូរជីវចល

ធនធានបង្រៀន